# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## របាយការណ៍ស្តីអំពីការបណ្តុះបណ្តាលការងារគ្រប់គ្រងទិន្នន័យកុមារប្រឈម

Report on Training on Exposed Infant Data Management System

## នៅមន្ទីរពេទ្យ កុមារជាតិ

ថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០១២

វគ្គបណ្តុះបណ្តាលស្តីអំពីការងារគ្រប់គ្រងទិន្នន័យកុមារប្រឈម បានប្រព្រឹត្តទៅនៅមន្ទីរពេទ្យកុមារជាតិ ចាប់ពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១២, ដែលរៀបចំឡើងដោយផ្នែកគ្រប់គ្រងទិន្នន័យ សហការជាមួយផ្នែកថៃទាំជំងឺអេដស៍ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដោយទទួលបាននូវការឧបត្ថម្ភថវិកាពីមូលនិធិគ្លីនតុន (CLINTON Health Access Initiative) ។ វគ្គបណ្តុះបណ្តាលនេះ គឺធ្វើឡើងក្នុងគោលបំណងផ្តល់នូវពតិមានថ្មីៗដែល មជ្ឈមណ្ឌលជាតិបាន និងកំពុងរៀបចំដាក់អោយប្រើប្រាស់-ធ្វើការផ្លាស់ប្តូរបទពិសោធន៏គ្នាទៅវិញទៅមក លើការងារគ្រប់គ្រងទិន្នន័យកុមារដែលកើតពីម្តាយមានផ្ទុកមេរោគអេដស៍-ពីយន្តការការងារដែលត្រូវអនុវត្ត ជាពិសេសលើ តួនាទីក្នុងការទទួលខុសត្រូវ និងភារកិច្ចដែលត្រូវអនុវត្តជាប្រចាំរបស់គ្រូពេទ្យ-មន្ត្រីចុះបញ្ជី-មន្ត្រីបញ្ចូលទិន្នន័យ និងមន្ត្រីគ្រប់គ្រងទិន្នន័យ ។




វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីៈ គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ- មន្ត្រីចុះបញ្ជី-មន្ត្រីបញ្ចូលទិន្នន័យ និងមន្ត្រីគ្រប់គ្រងទិន្នន័យ ។

គណៈធិបតី ៖

| | | |
|---|---|---|
| ឯកឧត្តមវេជ្ជបណ្ឌិត | មាន ឈីវុន | ប្រធានមជ្ឈមណ្ឌលជាតិ |
| លោកស្រី | Emily Welle | តំណាងមូលនិធិគ្លីនតុន |

មន្ត្រីសំរបសំរួលវគ្គ និងគ្រូឧទ្ទេសនាមៈ

| | | |
|---|---|---|
| លោកវេជ្ជបណ្ឌិត | ស៊ីរិទ្ធ សុវណ្ណារិទ្ធ | ប្រធានផ្នែកថៃទាំជំងឺអេដស៍ |
| លោកវេជ្ជបណ្ឌិត | ង៉ូវ បូរ៉ា | អនុប្រធានផ្នែកថៃទាំជំងឺអេដស៍ |
| លោកគ្រូពេទ្យ | ជា ចំណាន | អនុប្រធានផ្នែកគ្រប់គ្រងទិន្នន័យ |
| លោក | ស៊ុន សុខលេង | មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ |

លោក កែ អាងហេង មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ

លោក លាង សុផាន់ណា មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ

**សកម្មភាពនៃវគ្គបណ្តុះបណ្តាល :**

**ថ្ងៃទី ១ :**

ពេលព្រឹក

ចាប់ពីម៉ោង ៧:៣០នាទី ដល់ម៉ោង ៨:០០: ការចុះឈ្មោះសិក្ខាកាមដែលមកចូលរួមទាំងអស់, ដែលក្នុងនោះមាន :

- មន្ទីរពេទ្យខេត្ត បាត់ដំបង :
  - គ្រូពេទ្យពិនិត្យ និង ព្យាបាលជំងឺកុមារ ចំនួន ០១ នាក់
  - មន្ត្រីទទួលបន្ទុកចុះបញ្ជី ចំនួន ០១ នាក់
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០១ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០១ នាក់
- មន្ទីរពេទ្យខេត្ត កំពង់ចាម
  - គ្រូពេទ្យពិនិត្យ និង ព្យាបាលជំងឺកុមារ ចំនួន ០១ នាក់
  - មន្ត្រីទទួលបន្ទុកចុះបញ្ជី ចំនួន ០១ នាក់
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០១ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០១ នាក់
- មន្ទីរពេទ្យបង្អែកត្បូងឃ្មុំ ខេត្ត កំពង់ចាម
  - គ្រូពេទ្យពិនិត្យ និង ព្យាបាលជំងឺកុមារ ចំនួន ០១ នាក់
  - មន្ត្រីទទួលបន្ទុកចុះបញ្ជី ចំនួន ០១ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០១ នាក់
- មន្ទីរពេទ្យកុមារជាតិ
  - គ្រូពេទ្យពិនិត្យ និង ព្យាបាលជំងឺកុមារ ចំនួន ០២ នាក់
  - មន្ត្រីទទួលបន្ទុកចុះបញ្ជី ចំនួន ០១ នាក់
  - មន្ត្រីបញ្ចូលទិន្នន័យ ចំនួន ០២ នាក់
- មន្ទីរពេទ្យខេត្ត តាកែវ
  - គ្រូពេទ្យពិនិត្យ និង ព្យាបាលជំងឺកុមារ ចំនួន ០១ នាក់
  - មន្ត្រីទទួលបន្ទុកចុះបញ្ជី ចំនួន ០១ នាក់
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០១ នាក់
- មន្ទីរពេទ្យបង្អែកគីរីវង់ ខេត្ត តាកែវ
  - គ្រូពេទ្យពិនិត្យ និង ព្យាបាលជំងឺកុមារ ចំនួន ០១ នាក់
  - មន្ត្រីទទួលបន្ទុកចុះបញ្ជី ចំនួន ០១ នាក់
  - មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០១ នាក់
- មន្ទីរពេទ្យបង្អែកអ្នកលឿង ខេត្តព្រៃវែង
  - គ្រូពេទ្យពិនិត្យ និង ព្យាបាលជំងឺកុមារ ចំនួន ០១ នាក់
  - មន្ត្រីទទួលបន្ទុកចុះបញ្ជី ចំនួន ០១ នាក់

- មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០១ នាក់
- មន្ត្រីគ្រប់គ្រងទិន្នន័យ ចំនួន ០១ នាក់

បន្ទាប់ពីការចុះឈ្មោះសិក្ខាកាមដែលមកចូលរួមរួចមក នៅវេលាម៉ោង ៨:៣០ វគ្គបណ្តុះបណ្តាលបានចាប់ផ្តើមដំណើរការរបស់ខ្លួន។ ជាកិច្ចចាប់ផ្តើម លោកស្រី Emily Welle តំណាងមូនិធិគ្លីនតុន, បានមានមតិសំណេះសំណាលដោយបានថ្លែងអំណរគុណដល់សិក្ខាកាមទាំងអស់ ដែលបានធ្វើដំណើរមកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ដើម្បីទទួលយកនូវចំណេះដឹង សំរាប់យកទៅអនុវត្តន៏ការងាររបស់ខ្លួនដែលត្រូវបំពេញ ដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់មជ្ឈមណ្ឌលជាតិ។ លោកស្រីកបានផ្តាំផ្ញើអោយសិក្ខាកាមទាំងអស់ ត្រូវធ្វើយ៉ាងណាយកចិត្តទុកដាក់ក្នុងការរៀនសូត្រ តាមរយៈការបណ្តុះបណ្តាលនេះ ដើម្បីយកទៅអនុវត្តការងារដែលត្រូវបំពេញនៅតាមខេត្តរៀងៗខ្លួន។ បន្ទាប់មកទៀតឯកឧត្តមវេជ្ជបណ្ឌិត មាន ឈីវុន ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានមានមតិសំណេះសំណាលទៅកាន់សិក្ខាកាមយ៉ាងស្និតស្នាល ដោយបានលើកយកពីដំណើរការ រៀបចំអោយមាននូវការងារពិនិត្យ-ព្យាបាលសំរាប់កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ ដែលជាចំណែកមួយដ៏សំខាន់ក្នុងការការពារកុមារផង និងម្តាយដែលមានផ្ទុកមេរោគអេដស៏ផង ហើយដែលត្រូវធ្វើយ៉ាងណាប្រមូល និងគ្រប់គ្រង នូវទិន្នន័យកុមារប្រឈមអេដស៍ ទាំងអស់អោយបានត្រឹមត្រូវ ។



បន្ទាប់ពីមានមតិសំណេះសំណាល និងផ្តាំផ្ញើរួចមក ឯកឧត្តមវេជ្ជបណ្ឌិតបានធ្វើការប្រកាសបើកវគ្គបណ្តុះបណ្តាលចាប់ពីពេលនោះតទៅ។

បន្ទាប់ពីការប្រកាសបើកវគ្គបណ្តុះបណ្តាលរួចមក វគ្គបណ្តុះបណ្តាលបានចាប់ផ្តើមដំណើរការការងាររបស់ខ្លួន តាមកម្មវិធី និងពេលវេលាកំណត់ ដោយបានចាប់ផ្តើមធ្វើការបង្ហាញពីលទ្ធផលនានាដែលបានអនុវត្តកន្លងមក និងទិសដៅការងារដែលត្រូវអនុវត្តបន្តលើការងារថែទាំ និងព្យាបាលជំងឺអេដស៍ មានជាអាទិ៍ :

<u>ពេលព្រឹក</u>

- ការធ្វើតេស្តមុនវគ្គសិក្សា (Pre-test): ដែលតំរូវអោយសិក្ខាកាមទាំងអស់បំពេញនូវសំនួរមួយចំនួន ដើម្បីចង់ដឹងថាមុនពេលវគ្គសិក្សា តើកំរិតនៃការយល់ដឹងរបស់ពួកគាត់ស្ថិតនៅកំរិតណា។
- ការបង្ហាញអំពីគោលការណ៍ណែនាំអំពីការថែទាំព្យាបាលកុមារប្រឈម និងការឆ្លងមេរោគអេដស៍



ពេលរសៀល

- ការបង្ហាញអំពីការងារបំពេញទំរង់ពតិមានកុមារប្រឈម (Exposed Infant patient form completing and practice) ដែលតំរូវអោយមានការសួរនាំអោយបានច្រើន ដល់អាណាព្យាបាលរបស់កុមារ ។ ទំរង់ពតិមានកុមារប្រឈម ចែកចេញជា ២ៈ ទំរង់ ក និង ទំរង់ ខ ហើយដែលពតិមានដែលមាននៅក្នុងទំរង់ទាំង ២ នេះ ចាំបាច់សំរាប់ធ្វើជារបាយការណ៍អំពីការថែទាំកុមារ ។
- ក្រុមការងារបានធ្វើការពិភាក្សាបន្ថែមអំពីការងារបំពេញទំរង់ពតិមានកុមារប្រឈម ក្នុងទិសដៅពង្រឹងគុណភាពនៃការពិនិត្យ នឹងព្យាបាលរបស់គ្រូពេទ្យផង និងក្នុងគោលបំណងពង្រឹងគុណភាពសំរាប់ការបញ្ចូលទិន្នន័យ ។



## ថ្ងៃទី ២ :

ពេលព្រឹក

- ការបង្ហាញអំពីការងារបំពេញបញ្ជីចុះឈ្មោះកុមារប្រឈម (Exposed Infant Registration completing and practice) ដែលតំរូវអោយមន្ត្រីទទួលបន្ទុកការងារចុះបញ្ជីត្រូវស្រង់យកពតិមានចេញពីក្នុងទំរង់ពតិមានអ្នកជំងឺ មកបញ្ចូលក្នុងបញ្ជី អោយបានត្រឹមត្រូវគ្រប់ពេលវេលានៃការមកពិនិត្យរបស់កុមារ ។




- ការបង្ហាញអំពីការងារបញ្ចូលពតិមានទៅក្នុងប្រព័ន្ធ Database ដើម្បីធ្វើអោយទិន្នន័យដែលបានបញ្ចូលទៅក្នុង Database មានគុណភាពល្អ និងត្រឹមត្រូវ និងបានបង្ហាញនូវដំណោះស្រាយមួយចំនួនដែលមន្ត្រីគ្រប់គ្រងទិន្នន័យខេត្ត-មន្ត្រីបញ្ចូលទិន្នន័យអាចជួបប្រទះ ។
- ការបង្ហាញអំពីការធ្វើរបាយការណ៍ប្រចាំត្រីមាស ។

ពេលរសៀល

- រំឭកឡើងវិញអំពីការងារបញ្ចូលពតិមានទៅក្នុងប្រព័ន្ធ Database ដើម្បីធ្វើអោយទិន្នន័យដែលបានបញ្ចូលទៅក្នុង Database មានគុណភាពល្អ និងត្រឹមត្រូវ ។
- ពិភាក្សាលើការងារបំពេញទំរង់ពតិមានអ្នកជំងឺ-ការចុះបញ្ជីកុមារ-ការរៀបចំទុកដាក់ឯកសារ និងការអនុវត្តន៍ផ្សេងៗទៀត នៅពេលកុមារមានលទ្ធផលឈាមវិជ្ជមាន ។
- ការធ្វើតេស្តក្រោយវគ្គសិក្សា (Post-test) ដែលតំរូវអោយសិក្ខាកាមទាំងអស់ បំពេញនូវចំលើយមួយចំនួន ដើម្បីចង់ដឹងថាបន្ទាប់ពីបានទទួលវគ្គបណ្តុះបណ្តាលរយៈពេល២ថ្ងៃនេះមក តើកំរិតនៃការយល់ដឹងរបស់ពួកគាត់ ។



**<u>សេចក្តីសន្និដ្ឋាន</u>**

បន្ទាប់ពីបានទទួលការសិក្សារយៈពេល ២ថ្ងៃកន្លងមក ឃើញថា គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ-មន្ត្រីចុះបញ្ជី-មន្ត្រីបញ្ចូលទិន្នន័យ និងមន្ត្រីគ្រប់គ្រងទិន្នន័យទាំងអស់បាន យល់ដឹងបន្ថែមលើការងារពិនិត្យ និងព្យាបាលកុមារដែលកើតពីម្តាយមានផ្ទុកមេរោគអេដស៍ ដែលមជ្ឈមណ្ឌលជាតិ បាន និងកំពុងរៀបចំដាក់អោយប្រើប្រាស់ តាមរយៈការបង្ហាញរបស់គ្រូសម្របសម្រួលមកពីមជ្ឈមណ្ឌលជាតិ និងការយកចិត្តទុកដាក់របស់សិក្ខាកាម ដែលអាចជួយបង្កើននូវសមត្ថភាពក្នុងការប្រមូល-ពិនិត្យ-ព្យាបាលកុមារប្រឈម កាន់តែមានភាពសុក្រិតថែមទៀត។

វគ្គបណ្តុះបណ្តាលនេះ បានបញ្ចប់នៅវេលាម៉ោង ១៧:០០ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ក្រោមបរិយាកាសរីករាយ និងស្និតស្នាលជាទីបំផុត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ខែ មីនាឆ្នាំ ២០១២

| បានឃើញ និង ឯកភាព | បានពិនិត្យ | អ្នកធ្វើរបាយការណ៍ |
| --- | --- | --- |
| ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ | ផ្នែកថែទាំជម្ងឺអេដស៍ | ផ្នែកគ្រប់គ្រងទិន្នន័យ |
| វេជ្ជ. មាន ឈីវុន | សិរិទ្ធ សុវណ្ណារិទ្ធ | ជា ចំណាន |